# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៥៥២៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ..០៧... ខែ កក្កដា.. ឆ្នាំ ២០១៦..

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** របាយការណ៍ប្រចាំសប្តាហ៍ស្តីពីសភាពការណ៍នៃល្បឿនការងារបង្កបង្កើនផលដំណាំរដូវវស្សាឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍នៃល្បឿនការងារបង្កបង្កើនផលដំណាំរដូវវស្សាឆ្នាំ២០១៦ គិតត្រឹមថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦ មានដូចតទៅ ÷

I. **ល្បឿនការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦** (ដូចមានតារាងជូនភ្ជាប់)÷

ក - ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន១ ៧៩៤ ៧៩៩ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ១១០ ១២៥ហ.ត (ស្មើនឹង៦,១៤%) និងដោយគ្រឿងយន្តកសិកម្មចំនួន១ ៦៨៤ ៦៧៤ហ.ត(ស្មើនឹង៩៣,៨៦%) លើសឆ្នាំមុន៣០៩ ៤១៦ហ.ត។

ខ - សាបសម្រេចបានចំនួន២២ ៦២៤ហ.ត តិចជាងឆ្នាំមុន៤៣៧ហ.ត។

គ - ស្ទូងនិងព្រោះសម្រេចបានចំនួន១ ២៩៦ ៨៨៤ហ.ត ស្មើនឹង៥២,៣៧ភាគរយនៃផែនការ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន១៦០ ១៨៧ហ.ត និងស្រូវតាមប្រភេទមាន÷

- ស្រូវស្រាលចំនួន ៣៤៩ ៧៥៦ ហ.ត(ក្នុងនោះស្រូវបង្កើនរដូវចំនួន១៣៨ ៩៣៩ហ.ត) លើសឆ្នាំមុន ២៨ ៦៧៣ហ.ត
- ស្រូវកណ្តាលចំនួន៥៧២ ៤៤៥ហ.ត លើសឆ្នាំមុន១០០ ៨៥២ហ.ត
- ស្រូវធ្ងន់ចំនួន៣១២ ២៦៧ហ.ត លើសឆ្នាំមុន៤២ ៩០៨ហ.ត
- ស្រូវចម្ការចំនួន២៤ ៣២២ហ.ត តិចជាងឆ្នាំមុន៤ ៥៨៦ហ.ត
- ស្រូវឡើងទឹកចំនួន ៣៨ ០៩៤ហ.ត តិចជាងឆ្នាំមុន ៧ ៦៦០ហ.ត។

II. **ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ២០១៦** (ដូចមានតារាងជូនភ្ជាប់)÷

ក - ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន៦៨៨ ៥៥២ហ.ត ស្មើនឹង១១១,៧៦ភាគរយ នៃផែនការ៦១៦ ១២៣ហ.ត លើសឆ្នាំមុន១០៩ ៤៩៣ហ.ត។

ខ- ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន៤៥ ០៧៩ហ.ត ស្មើនឹង៣២,៨៥ភាគរយ នៃផែនការ១៣៧ ២៣៨ហ.ត តិចជាងឆ្នាំមុន២ ៥៤០ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

## III. សេចក្ដីសន្និដ្ឋាន

មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អបង្គួរ នៅតាមបណ្ដារាជធានី ខេត្តទូទាំងប្រទេស។ ជារួម នៅសប្ដាហ៍ទី១ខែកក្កដានេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ សម្រេចបាន៥២,៣៧ភាគរយ (សប្ដាហ៍មុន៤២,០២%) មានសភាពលឿនជាងឆ្នាំមុនប្រមាណ **១៦០ ១៨៧**ហ.ត ស្មើនឹង៨,០៩ភាគរយ បើប្រៀបធៀបរយៈពេលដូចគ្នា។ ក្នុងសប្ដាហ៍នេះយើងសង្កេតឃើញថា ស្ថានភាពនៃការផ្ទុះឡើងនូវសត្វដង្កូវហ្វូង ដែលបានកើតមាននៅតាមបណ្ដាខេត្តទាំង ១១ នាពេលនេះបានធូរស្រាលឡើងវិញហើយ ដោយមានទឹកភ្លៀងធ្លាក់រាយប៉ាយល្អបង្គួរនៅគ្រប់តំបន់រាជធានី ខេត្ត ពិសេសខេត្តដែលទទួលរងផលប៉ះពាល់នេះ។ ផ្ទៃដីដែលទទួលរងផលប៉ះពាល់មិនមានការប្រែប្រួលកើនឡើងទេ គឺដូចគ្នានឹងសប្ដាហ៍មុន (២១ ៦៣២ហ.ត) ហើយផ្ទៃដីខូចខាតមានចំនួន១ ២៤១ហ.ត។ ទោះជាយ៉ាងណា ប្រជាកសិករបាន និងកំពុងខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប ព្រោះ និងដកស្ទូង ដើម្បីឱ្យទាន់រដូវកាលដាំដុះ ដោយអនុវត្តបច្ចេកទេសកសិកម្មសមស្រប ហើយក្រសួងបានខិតខំណែនាំដល់អង្គភាពជំនាញ មន្ទីរកសិកម្មរាជធានី ខេត្ត ឱ្យចុះពិនិត្យតាមដានការងារដាំដុះ និងផលប៉ះពាល់កើតឡើងជាយថាហេតុ ដើម្បីមានវិធានការទប់ស្កាត់និងអន្តរាគមន៍ទាន់ពេលវេលា ។ ដោយឡែកជំងឺឆ្លងសត្វផ្សេងៗ ក្រសួងបន្តការចុះពិនិត្យតាមដាន ការចាក់វ៉ាក់សាំងការពារ និងចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្ដារាជធានី ខេត្ត។

សេចក្ដីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្ដីអនុគ្រោះ។

សូម **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន÷**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជ្រាប"
- ឯកសារ កាលប្បវត្តិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ល្បឿនការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦

(គិតត្រឹមថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផែនការ | ផ្ទៃដីភ្ជួររាស់ (ហ.ត) | | | | | ផ្ទៃដីសាប | ផ្ទៃដីព្រោះស្ទូង និងបុកដាំ (ហ.ត) | | | | | | សរុបស្ទូង និង ព្រោះបុកដាំ (ហ.ត) | ភាគរយ (%) | ថ្ងៃខែឆ្នាំ រាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប | គោ-ក្របី | | គ្រឿងយន្ត | | | ស្រូវស្រាល | | កណ្តាល | ធ្ងន់ | ចម្ការ | ឡើងទឹក | | | |
| | | | | ហ.ត | % | ហ.ត | % | | សរុប | បង្កើនរដូវ | | | | | | | |
| 01 | បន្ទាយមានជ័យ | 245,000 | 217,739 | | - | 217,739 | 100.00 | | 49,319 | 38,878 | 102,607 | 43,549 | - | 10,643 | 206,118 | 84.13 | 04-07-2016 |
| 02 | បាត់ដំបង | 269,800 | 231,300 | 75 | 0.03 | 231,225 | 99.97 | 12 | 33,282 | 18,592 | 50,011 | 45,628 | 150 | 4,698 | 133,769 | 49.58 | 05-07-2016 |
| 03 | កំពង់ចាម | 86,540 | 55,007 | 9,070 | 16.49 | 45,937 | 83.51 | 341 | 12,621 | 5,096 | 17,823 | 15,433 | - | 243 | 46,120 | 53.29 | 30-06-2016 |
| 04 | កំពង់ឆ្នាំង | 121,800 | 93,813 | 16,985 | 18.11 | 76,828 | 81.89 | 4,338 | 1,867 | 918 | 9,124 | 12,536 | - | 311 | 23,838 | 19.57 | 04-07-2016 |
| 05 | កំពង់ស្ពឺ | 113,600 | 56,554 | 14,150 | 25.02 | 42,404 | 74.98 | 3,209 | 2,025 | 653 | 3,106 | 4,861 | 89 | - | 10,081 | 8.87 | 04-07-2016 |
| 06 | កំពង់ធំ | 213,300 | 162,678 | 10,534 | 6.48 | 152,144 | 93.52 | 806 | 19,799 | 6,998 | 65,741 | 53,901 | 1,716 | 10,510 | 151,667 | 71.11 | 04-07-2016 |
| 07 | កំពត | 126,000 | 62,361 | 5,393 | 8.65 | 56,968 | 91.35 | 3,008 | 20,459 | - | 5,297 | 10,934 | 8 | - | 36,698 | 29.13 | 04-07-2016 |
| 08 | កណ្តាល | 39,340 | 18,848 | 1,864 | 9.89 | 16,984 | 90.11 | 257 | 8,909 | 4,328 | 2,598 | 754 | - | 43 | 12,304 | 31.28 | 04-07-2016 |
| 09 | កោះកុង | 10,476 | 2,949 | 646 | 21.91 | 2,303 | 78.09 | 590 | 358 | - | 1,740 | 166 | 1,216 | - | 3,480 | 33.22 | 04-07-2016 |
| 10 | ក្រចេះ | 33,000 | 21,369 | 2,935 | 13.73 | 18,434 | 86.27 | 673 | 3,676 | 970 | 589 | - | 177 | - | 4,442 | 13.46 | 04-07-2016 |
| 11 | មណ្ឌលគិរី | 23,000 | 1,487 | - | - | 1,487 | 100.00 | 79 | 158 | - | 831 | 109 | 1,761 | - | 2,859 | 12.43 | 04-07-2016 |
| 12 | ភ្នំពេញ | 11,120 | 935 | 399 | 42.67 | 536 | 57.33 | 65 | 547 | - | 196 | - | - | - | 743 | 6.68 | 05-07-2016 |
| 13 | ព្រះវិហារ | 80,870 | 27,267 | 1,673 | 6.14 | 25,594 | 93.86 | 2,187 | 2,698 | - | 8,064 | 911 | 2,408 | - | 14,081 | 17.41 | 04-07-2016 |
| 14 | ព្រៃវែង | 250,000 | 186,495 | 2,200 | 1.18 | 184,295 | 98.82 | 118 | 40,563 | - | 110,304 | 22,922 | - | - | 173,789 | 69.52 | 05-07-2016 |
| 15 | ពោធិ៍សាត់ | 100,000 | 85,144 | 494 | 0.58 | 84,650 | 99.42 | 142 | 38,096 | 326 | 17,533 | 7,471 | 129 | 4,251 | 67,480 | 67.48 | 04-07-2016 |
| 16 | រតនគិរី | 26,200 | 10,566 | 1,401 | 13.26 | 9,165 | 86.74 | 1,471 | 430 | - | 846 | 290 | 9,554 | - | 11,120 | 42.44 | 04-07-2016 |
| 17 | សៀមរាប | 186,200 | 173,385 | 15,895 | 9.17 | 157,490 | 90.83 | 1,770 | 19,110 | - | 67,020 | 33,480 | 3,225 | 7,395 | 130,230 | 69.94 | 03-07-2016 |
| 18 | ព្រះសីហនុ | 16,600 | 16,600 | 4,150 | 25.00 | 12,450 | 75.00 | 69 | 1,500 | - | 5,844 | 4,200 | - | - | 11,544 | 69.54 | 05-07-2016 |
| 19 | ស្ទឹងត្រែង | 27,800 | 17,179 | 2,274 | 13.24 | 14,905 | 86.76 | 1,975 | 316 | - | 250 | - | 2,314 | - | 2,880 | 10.36 | 05-07-2016 |
| 20 | ស្វាយរៀង | 167,000 | 90,983 | 14,378 | 15.80 | 76,605 | 84.20 | 86 | 24,780 | 13,567 | 43,009 | 3,012 | - | - | 70,801 | 42.40 | 04-07-2016 |
| 21 | តាកែវ | 170,000 | 120,126 | 4,693 | 3.91 | 115,433 | 96.09 | 1,008 | 46,399 | 45,456 | 6,287 | 145 | - | - | 52,831 | 31.08 | 05-07-2016 |
| 22 | ឧត្តរមានជ័យ | 72,000 | 72,520 | | - | 72,520 | 100.00 | 7 | 12,540 | - | 31,450 | 19,580 | 1,575 | - | 65,145 | 90.48 | 05-07-2016 |
| 23 | កែប | 3,500 | 2,928 | 643 | 21.96 | 2,285 | 78.04 | 260 | 524 | 340 | 943 | 620 | - | - | 2,087 | 59.63 | 04-07-2016 |
| 24 | ប៉ៃលិន | 5,000 | 2,279 | | - | 2,279 | 100.00 | 1 | 1,782 | - | 937 | 98 | - | - | 2,817 | 56.34 | 04-07-2018 |
| 25 | ត្បូងឃ្មុំ | 78,300 | 64,287 | 273 | 0.42 | 64,014 | 99.58 | 152 | 7,998 | 2,817 | 20,295 | 31,667 | - | - | 59,960 | 76.58 | 01-07-2016 |
| | សរុប | 2,476,446 | 1,794,799 | 110,125 | 6.14 | 1,684,674 | 93.86 | 22,624 | 349,756 | 138,939 | 572,445 | 312,267 | 24,322 | 38,094 | 1,296,884 | 52.37 | |
| | តួលេខសប្តាហ៍មុន | 2,476,446 | 1,482,436 | 73,496 | 4.96 | 1,408,940 | 95.04 | 13,492 | 286,272 | 127,235 | 450,206 | 248,168 | 21,880 | 34,200 | 1,040,726 | 42.02 | |
| | តួលេខឆ្នាំមុន | 2,567,130 | 1,485,383 | 120,057 | 8.08 | 1,365,326 | 91.92 | 23,061 | 321,083 | 91,230 | 471,593 | 269,359 | 28,908 | 45,754 | 1,136,697 | 44.28 | |
| | ប្រៀបធៀបឆ្នាំមុន | -90,684 | 309,416 | -9,932 | -1.95 | 319,348 | 1.95 | -437 | 28,673 | 47,709 | 100,852 | 42,908 | -4,586 | -7,660 | 160,187 | 8.09 | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

## ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ២០១៦

(គិតត្រឹមថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 1,340 | 1,000 | 1,867 | 1,699 | 70,015 | 79,952 | 170 | 25 | 970 | 521 | 155 | 172 | 72,650 | 82,537 | 113.61 |
| 02 | បាត់ដំបង | 48,600 | 48,100 | 37,014 | 36,867 | 138,200 | 104,452 | 110 | 100 | 1,430 | 567 | 16,760 | 4,219 | 205,100 | 146,352 | 71.36 |
| 03 | កំពង់ចាម | 5,180 | 3,090 | 4,752 | 2,251 | 12,330 | 9,473 | 380 | 55 | 3,990 | 3,776 | 6,640 | 2,466 | 28,520 | 20,522 | 71.96 |
| 04 | កំពង់ឆ្នាំង | 1,260 | 250 | 560 | - | 350 | 556 | 740 | 141 | 2,390 | 1,222 | 730 | 315 | 5,470 | 2,794 | 51.08 |
| 05 | កំពង់ស្ពឺ | 335 | - | 318 | - | 130 | 78 | 33 | 27 | 526 | 622 | 725 | 498 | 1,749 | 1,543 | 88.22 |
| 06 | កំពង់ធំ | 400 | - | 325 | - | 33,100 | 45,335 | 20 | 9 | 410 | 299 | 110 | 2,761 | 34,040 | 48,729 | 143.15 |
| 07 | កំពត | 2,660 | - | 529 | - | 1,610 | 660 | 780 | 251 | 2,930 | 1,224 | 2,570 | 728 | 10,550 | 3,392 | 32.15 |
| 08 | កណ្តាល | 12,460 | 11,640 | 8,972 | 8,105 | - | - | - | - | 4,204 | 3,158 | 203 | 75 | 16,867 | 12,205 | 72.36 |
| 09 | កោះកុង | 65 | - | | | 265 | | 35 | | 170 | | - | | 535 | - | 0.00 |
| 10 | ក្រចេះ | 1,300 | 930 | 3,376 | 2,943 | 5,000 | 58,962 | 50 | 61 | 450 | 251 | 99 | 547 | 6,899 | 63,197 | 916.03 |
| 11 | មណ្ឌលគិរី | 810 | 600 | 219 | 91 | 10,610 | 11,275 | 100 | 20 | 590 | 201 | 4,280 | 3,450 | 16,390 | 15,165 | 92.53 |
| 12 | ភ្នំពេញ | 128 | - | 115 | | 24 | 3 | 2 | 5 | 400 | 155 | 20 | 4 | 574 | 282 | 49.13 |
| 13 | ព្រះវិហារ | 10,061 | 4,281 | 10,394 | 2,514 | 17,749 | 18,067 | 460 | 483 | 735 | 544 | 9,352 | 5,206 | 38,357 | 34,694 | 90.45 |
| 14 | ព្រៃវែង | 2,380 | 2,380 | 1,698 | 1,639 | 500 | 947 | 10 | | 940 | 381 | 1,510 | 800 | 5,340 | 3,826 | 71.65 |
| 15 | ពោធិ៍សាត់ | 1,970 | 1,750 | 3,979 | 3,769 | 10,000 | 18,384 | 215 | 24 | 500 | 279 | 1,470 | 1,173 | 14,155 | 23,839 | 168.41 |
| 16 | រតនគិរី | 160 | | 714 | 625 | 13,400 | 17,261 | 40 | 16 | 70 | 49 | 510 | 340 | 14,180 | 18,380 | 129.62 |
| 17 | សៀមរាប | 900 | - | 313 | - | 7,335 | 14,707 | 310 | 210 | 1,840 | 1,003 | 1,575 | 2,710 | 11,960 | 18,943 | 158.39 |
| 18 | ព្រះសីហនុ | 25 | | | | 110 | 40 | 10 | | 275 | 98 | | | 420 | 138 | 32.86 |
| 19 | ស្ទឹងត្រែង | 1,340 | - | 595 | - | 14,000 | 10,709 | - | 39 | 550 | 304 | 1,000 | 368 | 16,890 | 12,015 | 71.14 |
| 20 | ស្វាយរៀង | 50 | | 8 | | 10,980 | 7,911 | 520 | 113 | 1,870 | 1,819 | | | 13,420 | 9,851 | 73.41 |
| 21 | តាកែវ | 393 | - | 102 | | 642 | 131 | 117 | 69 | 1,078 | 643 | 232 | 117 | 2,462 | 1,062 | 43.14 |
| 22 | ឧត្តរមានជ័យ | 111 | - | 70 | - | 35,643 | 53,900 | 23 | 6 | 125 | 78 | 99 | 75 | 36,001 | 54,129 | 150.35 |
| 23 | កែប | 150 | 60 | 112 | 24 | 200 | 3 | 100 | 77 | 100 | 184 | - | | 550 | 376 | 68.36 |
| 24 | ប៉ៃលិន | 4,015 | 4,000 | 1,267 | 1,258 | 5,000 | 59,087 | | | 15 | 18 | 1,000 | 21 | 10,030 | 60,393 | 602.12 |
| 25 | ត្បូងឃ្មុំ | 4,548 | 3,431 | 3,425 | 2,365 | 46,733 | 48,740 | 36 | 30 | 1,295 | 1,260 | 402 | 733 | 53,014 | 54,188 | 102.21 |
| | **សរុប** | **100,641** | **81,512** | **80,724** | **64,150** | **433,926** | **560,633** | **4,261** | **1,761** | **27,853** | **18,656** | **49,442** | **26,778** | **616,123** | **688,552** | **111.76** |
| | **តួលេខសប្តាហ៍មុន** | **100,641** | **81,512** | **75,469** | **59,327** | **433,926** | **535,787** | **4,261** | **1,548** | **27,853** | **16,699** | **49,442** | **26,177** | **616,123** | **655,680** | **106.42** |
| | **តួលេខឆ្នាំមុន** | **115,788** | **95,537** | **56,903** | **41,427** | **365,750** | **465,179** | **3,970** | **1,897** | **26,482** | **20,404** | **45,633** | **34,676** | **557,623** | **579,059** | **103.84** |
| | **ប្រៀបធៀបឆ្នាំមុន** | **-15,147** | **-14,025** | **23,821** | **22,723** | **68,176** | **95,454** | **291** | **-137** | **1,371** | **-1,748** | **3,809** | **-7,898** | **58,500** | **109,493** | **7.91** |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | 70 | 9 | 350 | 38 | 145 | 148 | 165 | 189 | 55 | 30 | - | | 785 | 414 | 52.74 |
| 02 | បាត់ដំបង | 600 | 75 | 20,600 | - | 12,850 | 409 | 160 | 100 | - | - | - | - | 34,210 | 584 | 1.71 |
| 03 | កំពង់ចាម | 2,810 | 564 | 16,340 | - | 11,140 | 7,584 | 570 | 854 | 10 | - | - | - | 30,870 | 9,002 | 29.16 |
| 04 | កំពង់ឆ្នាំង | 550 | 140 | | | 500 | 105 | 170 | 521 | 100 | 100 | 60 | 4 | 1,380 | 870 | 63.04 |
| 05 | កំពង់ស្ពឺ | 225 | 241 | - | | 25 | 21 | 485 | 353 | - | | - | - | 735 | 615 | 83.67 |
| 06 | កំពង់ធំ | 105 | 100 | 3,320 | | 335 | 77 | 16 | 45 | - | | - | | 3,776 | 222 | 5.88 |
| 07 | កំពត | 735 | 159 | - | - | 100 | 1 | 1,040 | 761 | - | | - | | 1,875 | 921 | 49.12 |
| 08 | កណ្តាល | 52 | - | - | - | 1,232 | 34 | 800 | 303 | 25 | - | - | - | 2,109 | 337 | 15.98 |
| 09 | កោះកុង | 30 | | - | | - | | 835 | | - | | - | | 865 | - | 0.00 |
| 10 | ក្រចេះ | 95 | 259 | - | 463 | 1,530 | 1,746 | 35 | 138 | - | | - | | 1,660 | 2,606 | 156.99 |
| 11 | មណ្ឌលគិរី | 3,500 | 1,806 | 2,500 | - | 35 | - | 140 | 41 | - | | - | | 6,175 | 1,847 | 29.91 |
| 12 | ភ្នំពេញ | - | | - | | 7 | 19 | 6 | 10 | | | | | 13 | 29 | 223.08 |
| 13 | ព្រះវិហារ | 2,778 | 2,875 | 14,757 | 2,352 | 372 | 1,274 | 1,549 | 2,202 | - | - | 8 | 7 | 19,464 | 8,710 | 44.75 |
| 14 | ព្រៃវែង | - | 9 | - | | 1,180 | 391 | 200 | 411 | - | | - | | 1,380 | 811 | 58.77 |
| 15 | ពោធិ៍សាត់ | 170 | 1,037 | 900 | 1,710 | 845 | 1,085 | 320 | 947 | - | | - | | 2,235 | 4,779 | 213.83 |
| 16 | រតនគិរី | 300 | 251 | 4,060 | 1,031 | 100 | 38 | 85 | 35 | | | 8 | 4 | 4,553 | 1,359 | 29.85 |
| 17 | សៀមរាប | - | - | 70 | 25 | 285 | 95 | 520 | 357 | - | - | - | - | 875 | 477 | 54.51 |
| 18 | ព្រះសីហនុ | | | | | | | 30 | 35 | | | | | 30 | 35 | 116.67 |
| 19 | ស្ទឹងត្រែង | 1,000 | 250 | 2,200 | 409 | 500 | 274 | 500 | 266 | - | - | - | - | 4,200 | 1,199 | 28.55 |
| 20 | ស្វាយរៀង | 65 | | | | | | 7,470 | 7,743 | | | | | 7,535 | 7,743 | 102.76 |
| 21 | តាកែវ | 100 | 25 | - | | 19 | | 311 | 145 | - | | - | | 430 | 170 | 39.53 |
| 22 | ឧត្តរមានជ័យ | 75 | 58 | 6,180 | | 55 | 40 | 44 | 33 | - | | - | | 6,354 | 131 | 2.06 |
| 23 | កែប | 30 | 11 | - | | - | | 70 | 76 | - | | - | | 100 | 87 | 87.00 |
| 24 | ប៉ៃលិន | 100 | 3 | 500 | 3 | 100 | - | 10 | 10 | | | | | 710 | 16 | 2.25 |
| 25 | ត្បូងឃ្មុំ | 930 | 1,005 | 1,370 | | 2,045 | 600 | 574 | 510 | - | | - | | 4,919 | 2,115 | 43.00 |
| | **សរុប** | **14,320** | **8,877** | **73,147** | **6,031** | **33,400** | **13,941** | **16,105** | **16,085** | **190** | **130** | **76** | **15** | **137,238** | **45,079** | **32.85** |
| | **តួលេខសប្តាហ៍មុន** | **14,320** | **8,791** | **73,147** | **4,614** | **33,400** | **13,867** | **16,105** | **15,429** | **190** | **130** | **76** | **15** | **137,238** | **42,846** | **31.22** |
| | **តួលេខឆ្នាំមុន** | **13,754** | **9,649** | **71,332** | **3,624** | **29,070** | **21,593** | **15,335** | **12,590** | **190** | **100** | **61** | **63** | **129,742** | **47,619** | **36.70** |
| | **ប្រៀបធៀបឆ្នាំមុន** | **566** | **-772** | **1,815** | **2,407** | **4,330** | **-7,652** | **770** | **3,495** | **0** | **30** | **15** | **-48** | **7,496** | **-2,540** | **-3.86** |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

## ក្រាហ្វិក ÷ ការប្រៀបធៀបល្បឿនការងារបង្កបង្កើនផលស្រូវរដូវវស្សា







